# តើវប្បធម៌មានតែចំពោះមនុស្សឬ?

*ដោយ*

*ប្រេង ពិសិដ្ឋ និង ម៉ិល វាសនា*

## សេចក្តីផ្តើម

បញ្ញត្តិ *វប្បធម៌* ត្រូវគេនិយាយនៅស្ទើរគ្រប់ទីកន្លែងនិងគ្រប់ពេលវេលាយ៉ាងងាយស្រួល តែគេពិបាកក្នុងការកំណត់នូវអត្ថន័យរួមមួយរបស់វាឱ្យបានគ្រប់ជ្រុងជ្រោយណាស់ ជាក់ស្តែងគឺមានការផ្តល់និយមន័យផ្សេងៗគ្នាដល់បញ្ញត្តិ *វប្បធម៌* ។ ដោយមិនមានការឯកភាពគ្នាលើនិយមន័យនៃបញ្ញត្តិ *វប្បធម៌* ការកំណត់ថា តើវប្បធម៌មានតែចំពោះមនុស្ស ឬមានចំពោះប្រភេទថនិកសត្វផ្សេងទៀត? ក៏មិនមានការឯកភាពគ្នាដែរ។ អត្ថបទដ៏ខ្លីនេះនឹងចូលរួមលើកឡើងនូវទស្សនៈផ្សេងៗដែលបានអះអាងបកស្រាយលើករណីនេះ។

## បញ្ញត្តិ « វប្បធម៌ »

តាមសៀវភៅ *អរិយធម៌ខ្មែរ* របស់អ្នកស្រី ត្រឹង ងា បានលើកឡើងពីអត្ថន័យនៃ *វប្បធម៌* ដូចខាងក្រោម៖

វប្បធម៌ < វប្ប + ធម៌

វប្ប = ការសាបព្រោះ ការបណ្តុះពូជ ការបង្កបង្កើត . . .

ធម៌ = ធាតុ វិធី ធម៌ភាព សភាវៈទ្រទ្រង់ . . .

**វប្បធម៌** = ធម៌ទាំងឡាយដែលទ្រទ្រង់នូវការសាបព្រោះបណ្តុះពូជឱ្យលេចលទ្ធផលជាផ្លែផ្កា។

តាមន័យវចនានុក្រមខ្មែរ វប្បធម៌សម្គាល់នូវការផ្សាំ ការបណ្តុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីឱ្យបានចម្រើនលូតលាស់ដោយវិទ្យាសាស្ត្រឬដោយសិល្បៈផ្សេងៗ។

អ្នកវិទ្យាសាស្ត្រជាតិរុស្ស៊ី *វ្លាឌីមៀរ ប៊ីប្លឺរ* (Vladimir Bibler) បានផ្តល់និយមន័យថា វប្បធម៌ជាទម្រង់កំណត់ខ្លួនឯងរបស់បុគ្គល ជាទម្រង់កំណត់ជីវិតយើង មនសិការយើង ការគិតរបស់យើង។

តាមន័យជាតិពន្ធុសាស្ត្រ វប្បធម៌ឬអរិយធម៌ជាការរួមផ្សំនៃពុទ្ធិ ជំនឿ សិល្បៈ សីលធម៌ ច្បាប់ ទំនៀមទម្លាប់ ព្រមទាំងសមត្ថភាពនិងទម្លាប់ផ្សេងៗដែលមនុស្សទទួលបានក្នុងនាមសមាជិកសង្គម។

វប្បធម៌អាចចាត់ទុកជាបទពិសោធន៍មនុស្ស ហើយជាងនេះទៀត គឺវាផ្សារភ្ជាប់ទៅនឹងសកម្មភាពប្រកបដោយភាពច្នៃប្រឌិតរបស់មនុស្សជាតិ។ វាមានអត្ថន័យពិសេសចំពោះការបង្កើតថ្មី ទាំងស្នាដៃខាងសម្ភារៈនិងស្មារតី។ បញ្ញត្តិ *វប្បធម៌* បានក្លាយទៅជាការសម្គាល់នូវសភាពឬធម៌ទាំងឡាយណាដែលអាចបណ្តុះបណ្តាល បង្កើនឱ្យបានផលល្អប្រសើរ ចម្រើនលូតលាស់ឡើងទៀត ទុកណាតាមផ្លូវវិជ្ជា ផ្លូវចិត្តគំនិត ឬ ផ្លូវកាយក៏ដោយ។

ជារួម បញ្ញត្តិ « វប្បធម៌ » ត្រូវគេប្រើក្នុងន័យសំខាន់បី៖

- វិចិត្រសិល្បៈនិងមនុស្សធម៌
- ចំណេះដឹង ជំនឿ និង ឥរិយាបថរបស់មនុស្ស ដែលផ្អែកលើសមត្ថភាពសិក្សាសង្គមនិងគំនិត
- បណ្តុំនៃអាកប្បកិរិយា តម្លៃ គោលបំណង និង ការប្រតិបត្តិ ដែលបង្ហាញពីចរិតលក្ខណៈស្ថាប័នមួយ អង្គការមួយ ឬ ក្រុមមួយ។

*ស៊ីសឺរ៉ូ* (Cicero) បានពន្យល់វប្បធម៌ក្នុងន័យជាសកម្មភាពគំនិត ពោលគឺ វប្បធម៌ផ្ទុយពីលក្ខណៈអាក្រក់ផ្សេងៗ ដែលជាអនារ្យធម៌និងជីវិតបែបធម្មជាតិ។

វិធីសាមញ្ញបំផុតដើម្បីគិតអំពីវប្បធម៌ គឺការគិតអំពីភាពខុសគ្នារវាងធម្មជាតិ(nature) (ជីវសាស្ត្រនិងហ្សែនរបស់យើង) និង ការអប់រំ(nurture) (បរិស្ថាននិងអ្វីៗនៅជុំវិញខ្លួនយើងដែលមានឥទ្ធិពលលើការកំណត់ភិនភាគអត្តសញ្ញាណយើង)។ តាមរយៈហ្សែននិងជីវសាស្ត្ររបស់យើង គឺយើងមានទម្រង់ជាក់លាក់និងសមត្ថភាពច្បាស់លាស់។ ប៉ុន្តែ ធម្មជាតិនៃជីវសាស្ត្ររបស់យើងមិនបានកំណត់ថាយើងជានរណានោះទេ។ ដូច្នេះ គឺយើងត្រូវការវប្បធម៌ដែលជាទិដ្ឋភាពមិនមែនជីវសាស្ត្រ តែគឺជាទិដ្ឋភាពសង្គមនៃជីវិតមនុស្ស ពោលគឺ អ្វីៗដែលមនុស្សបានរៀនគឺជាផ្នែកនៃវប្បធម៌៖ រឿងព្រេង ជំនឿ ព័ត៌មាន គំនិត ស្នាដៃសិល្បៈ ការប្រតិបត្តិសាសនា ម៉ូតពេញនិយម កិច្ចពិធីផ្សេងៗ ចំណេះដឹងឯកទេស និង អ្វីៗផ្សេងទៀត។

វប្បធម៌មិនមែនកំណត់នៅត្រឹមតែវត្ថុឬឥរិយាបថនោះទេ តែគឺវារួមបញ្ចូលនូវ បទដ្ឋាន តម្លៃ ជំនឿ ឬ និមិត្តសញ្ញា ផងដែរ។ បទដ្ឋានជារបៀបដែលមនុស្សប្រព្រឹត្តនៅក្នុងសង្គមរបស់ខ្លួន , តម្លៃជាអ្វីដែលមនុស្សស្រឡាញ់ចូលចិត្ត , ជំនឿជារបៀបដែលមនុស្សគិតអំពីដំណើរការរបស់ចក្រវាឡ និង និមិត្តសញ្ញាជាការតំណាងនូវអ្វីៗផ្សេងៗ នោះគឺការតំណាងអំពីបទដ្ឋានសង្គម តម្លៃ និង ជំនឿខ្លួនវានោះ។

សរុបមក វប្បធម៌ជាការរួមបញ្ចូលនូវវត្ថុនិងនិមិត្តសញ្ញាផ្សេងៗ ខ្លឹមសារផ្តល់ឱ្យវត្ថុនិងនិមិត្តសញ្ញាទាំងនោះ ព្រមទាំង បទដ្ឋាន តម្លៃ និង ជំនឿ ដែលជ្រួតជ្រាបជាទូទៅក្នុងជីវិតសង្គម។

## ប្រភពវប្បធម៌

បន្ថែមលើទ្រឹស្តីនៃការវិវត្ត នរវិទូសន្មតថា ភាវៈមនុស្សមានការវិវត្តស្មើៗគ្នា ហើយមនុស្សទាំងអស់សុទ្ធសឹងតែមានវប្បធម៌ដែលផ្នែកខ្លះកើតឡើងដោយសារការវិវត្តនោះ។

តាមទស្សនៈអំពីវប្បធម៌គឺថា មនុស្សរស់នៅទីកន្លែងផ្សេងគ្នាគឺបង្កើតបាននូវវប្បធម៌ដោយឡែកពីគ្នា។ ប៉ុន្តែ ធាតុនៃវប្បធម៌ផ្សេងៗគ្នានោះ អាចរីករាលដាលពីក្រុមមនុស្សមួយទៅក្រុមមួយទៀត។ វប្បធម៌គឺមានថាមពល ហើយអាចបង្ហាត់បង្រៀននិងរៀនបាន ធ្វើឱ្យវាក្លាយជាទម្រង់នៃការគ្រាប់តាមដែលនាំទៅរកការប្រែប្រួលលើផ្នែករូបសាស្ត្រ។ នរវិទូបានមើលវប្បធម៌នៅក្នុងន័យមិនគ្រាន់តែជាផលិផលនៃការវិវត្តជីវសាស្ត្រប៉ុណ្ណោះទេ តែក៏ជាការបំពេញបន្ថែមលើការវិវត្តនោះផងដែរ។

ទស្សនៈអំពីវប្បធម៌បង្ហាញថា វប្បធម៌នីមួយៗសុទ្ធសឹងមានដែនកំណត់របស់វា ហើយដែលត្រូវយល់ជារួមតាមសព្វរបស់វា។ តាមទស្សនៈសាបេក្ខនិយមវប្បធម៌ ( cultural relativism ) គឺមិនមានវប្បធម៌ «ល្អជាង» ឬ «អន់ជាង» នោះទេ តែគឺមានវប្បធម៌ផ្សេងៗគ្នា។

## តួនាទីវប្បធម៌

គេក៏អាចមើលឃើញផងដែរថា វប្បធម៌ដើរតួនាទីជាក់លាក់មួយនៅក្នុងជីវិតសង្គម។ យោងតាម Griswold វប្បធម៌ផ្តល់នូវការណែនាំ ទប់ស្កាត់ភាពរឹករវរ និង ដឹកនាំឥរិយាបថទៅតាមគន្លងសកម្មភាពជាក់លាក់ផ្សេងដែលខុសពីអ្នកដទៃ។ Griswold បានពន្យល់បន្ថែមលើចំណុចនេះថា ក្រុមនិងសង្គមទាំងឡាយត្រូវការការតំណាងរួមរបស់គេ ដើម្បីជំរុញមនោសញ្ចេតនារួបរួមគ្នានិងគាំទ្រទំនុកបម្រុងគ្នា ហើយគឺវប្បធម៌ជាអ្នកបំពេញតម្រូវការនេះ។ ម្យ៉ាងទៀត វប្បធម៌អាចមានតួនាទីរក្សាសណ្តាប់ធ្នាប់ដែលជាលទ្ធផលនៃការយល់ដឹងនិងខ្លឹមសាររួម។

វប្បធម៌ក៏អាចមានតួនាទីបង្កើតនិងជួយគាំទ្រដល់អសមភាពសង្គមផងដែរ។ តាមលោក Collins សញ្ញាណវប្បធម៌របស់ជាតិសាសន៍ ក្រុមថ្នាក់ និង ភេទ អាចប្រើដើម្បីពន្យល់បង្ហាញពីភាពត្រឹមត្រូវនៃគំរូសង្គមលើការគាបសង្កត់និងឯកសិទ្ធិ តាមរយៈការធ្វើឱ្យភាវៈសង្គមជឿថា អត្ថិភាពនៃអសមភាពបង្ហាញពីរបៀបដែលវត្ថុទាំងឡាយមានលក្ខណៈបែបនោះ។ ជាលទ្ធផល ការខិតខំប្រឹងប្រែងដើម្បីយុត្តិធម៌សង្គមនិងសមភាពសង្គមត្រូវតែឈ្នះលើគំរូវប្បធម៌ដែលអ្នកគ្រប់គ្រងនិងអ្នកត្រូវគេគ្រប់គ្រងយល់ថា អត្ថិភាពនៃលំដាប់ថ្នាក់សង្គមគឺជារឿងធម្មជាតិដែលមិនអាចជៀសរួច។

## តើវប្បធម៌មានតែចំពោះមនុស្សឬ?

សម្រាប់នរវិទ្យាអាមេរិក *វប្បធម៌* គឺសំដៅលើសមត្ថភាពមនុស្សក្នុងការចែករំលែក និង បង្ហាញបទពិសោធន៍របស់ខ្លួនជានិមិត្តសញ្ញា ហើយធ្វើទំនាក់ទំនងបទពិសោធន៍ទាំងនោះជាទូទៅក្នុងសង្គម។ នរវិទ្យាអាមេរិកផ្នែកជីវសាស្ត្របានពិភាក្សាជាសំខាន់លើ ២ចំណុច គឺ ទី១ តើវប្បធម៌មានតែចំពោះ

មនុស្ស ឬ ក៏មានចំពោះចំពូកផ្សេងៗទៀតដែរ (ពពួកបុព្វថនិកសត្វ)? នេះជាសំណួរដ៏មានសារៈសំខាន់ ព្រោះទ្រឹស្តីនៃការវិវត្តបានលើកឡើងថា មនុស្សវិវត្តមកពីបុព្វថនិកសត្វ ដែលបច្ចុប្បន្នបានវិនាសសាបសូន្យអស់ហើយ។ ទី២ តើវប្បធម៌មានការវិវត្តយ៉ាងដូចម្តេចក្នុងសង្គមមនុស្ស?

ការកំណត់និយមន័យវប្បធម៌សំដៅលើមនុស្សរបស់ *ថៃល័រ* បានក្លាយជាមូលដ្ឋានឱ្យនរវិទូជាច្រើនបង្កើតបានជាទ្រឹស្តីផ្សេងៗទៀត ដោយគ្រាន់តែឱ្យអត្ថន័យវប្បធម៌ស្មើនឹងឥរិយាបថហាត់រៀនប៉ុណ្ណោះ។ មានន័យថា វប្បធម៌សំដៅលើឥរិយាបថហាត់រៀនក្នុងចំណោមមនុស្ស ឯអ្នកដទៃទៀតមិនបានយល់ដូច្នេះឡើយ។ *រ៉ូប៊ឺត យ៉ឺគី* (Robert Yerkes) និង *ចេន ហ្គូដល* (Jane Goodall) ដែលមិនមែនជានរវិទូ បានលើកឡើងថា ដោយសារសត្វស្វាឪបានហាត់រៀនពីឥរិយាបថ គឺពួកវាមានវប្បធម៌។ អ្នកឯកទេសបុព្វថនិកសត្វផ្នែកនរវិទ្យាមានទស្សនៈផ្សេងគ្នា ដោយអ្នកខ្លះអះអាងថា បុព្វថនិកសត្វមិនមានវប្បធម៌ ឯអ្នកខ្លះទៀតអះអាងថា បុព្វថនិកសត្វមានវប្បធម៌។

*ឆាលី ហ្វ្រេឌឺរីយ* (Charles Frederick) បានចង្អុលបង្ហាញថា ប្រសិនបើវប្បធម៌មានលក្ខណៈត្រឹមតែជា *ឥរិយាបថហាត់រៀន* នោះគ្រប់សត្វទាំងអស់សុទ្ធតែមានវប្បធម៌។ ពិតណាស់ អ្នកឯកទេសទាំងអស់យល់ស្របថា ចំពូកបុព្វថនិកសត្វទាំងអស់មានជំនាញញាណរួម គឺ ចំណេះដឹងពីវត្ថុប្រើប្រាស់ជាប្រចាំ ញាណកំណត់ដែនទី សមត្ថភាពធ្វើចំណាត់ថ្នាក់វត្ថុ និង ការដោះស្រាយបញ្ហាប្រកបដោយប្រឌិតញាណ។ ជាងនេះទៀត ចំពូកបុព្វថនិកសត្វបានបង្ហាញតឹកតាងពីជំនាញសង្គម ដែលចូលរួមជាមួយគ្នាពោលគឺ ពួកវាស្គាល់សមាជិកក្រុមរបស់វា ពួកវាបង្កើតទំនាក់ទំនងផ្ទាល់តាមលំដាប់ញាតិសន្តាននិងឋានៈ ពួកវាស្គាល់ទំនាក់ទំនងសង្គមជាមួយអ្នកដទៃ ពួកវាព្យាករណ៍ពីឥរិយាបថអនាគត ហើយវារួមគ្នាដោះស្រាយបញ្ហា។ ហេតុនេះ បញ្ញត្តិ *វប្បធម៌* អាចប្រើបានចំពោះសត្វតែក្នុងករណីយើងកំណត់ន័យវប្បធម៌ជាឥរិយាបថហាត់រៀនប៉ុណ្ណោះ។

ចិត្តវិទូ *ម៉ៃឃើល ថូម៉ាសឺឡូ* (Michael Tomasello) បានអះអាងថា គន្លឹះធ្វើឱ្យមនុស្សរីកចម្រើនលឿនជាងបុព្វថនិកសត្វគឺ ភាសា បច្ចេកវិទ្យា អង្គការសង្គម ដែលជាលទ្ធផលនៃធនធានញាណរួមគ្នារបស់មនុស្ស។ កំណែលំអថ្មីៗ ទាំងគំនិត ទាំងឧបករណ៍ បានរីកសាយនិងចែករំលែកគ្នាក្នុងចំណោមសមាជិកក្រុម ហើយក្មេងៗជំនាន់ក្រោយកាន់តែស្ទាត់ជំនាញ ដែលអាចឱ្យគេរក្សាបាននូវអ្វីថ្មីនិងកែលំអឱ្យកាន់តែប្រសើរឡើង។ ចំពោះ *ថូម៉ាសឺឡូ* ការរៀនសូត្រពីសង្គមរបស់មនុស្ស ដែលជាការរៀនសូត្រធ្វើឱ្យមនុស្សដាច់ចេញផុតពីបុព្វថនិកសត្វដទៃទៀត ហើយធ្វើឱ្យមនុស្សមានការវិវត្តនោះ គឺផ្អែកលើធាតុពីរ៖ ទី១ « ការរៀនដោយការធ្វើត្រាប់តាម » (ខុសពីចរិតលក្ខណៈនៃ *ការរៀនធ្វើត្រាប់តាម* របស់បុព្វថនិកសត្វដទៃ) និង ទី២ មនុស្សបង្ហាញបទពិសោធន៍ខ្លួនដោយប្រើសញ្ញា (ខុសពីចរិតលក្ខណៈរបស់បុព្វថនិកសត្វដទៃទៀត)។ ធាតុទាំងពីរនេះធ្វើឱ្យមនុស្សមានការបង្កើតថ្មី និង រក្សាការបង្កើតថ្មីផ្សេងៗ ដែលមានសារៈប្រយោជន៍។

ចំពោះបុព្វថនិកសត្វដទៃទៀត ការរៀនជា « ការរៀនចម្លងតាម » ដែលផ្តោតជាសំខាន់ទៅលើព្រឹត្តិការណ៍បរិស្ថានជុំវិញខ្លួន។ លោក *ថូម៉ាសីឡូ* បានបញ្ជាក់ថា ការរៀនចម្លងតាម ជាយុទ្ធសាស្ត្រមានលក្ខណៈបត់បែនខ្ពស់សម្រាប់សត្វស្វាប្រភេទធំ ព្រោះវាផ្តោតជាសំខាន់ទៅលើផលនៃសកម្មភាព។ សត្វស្វាឪមានការប្រើឧបករណ៍ខុសៗគ្នាក្នុងការចាប់កណ្តៀរ ចាប់ស្រមោច ជីករកស្រមោច ការបំបែកគ្រាប់ផ្លែឈើ និង ការជូតសម្អាតស្លឹកឈើ។ សត្វស្វាឪនៅអាហ្វ្រិកខាងកើតចាប់កណ្តៀរដោយប្រើឈើតូចស្តើង ឯស្វាឪនៅអាហ្វ្រិកខាងលិចប្រើឈើធំដើម្បីបំបែកពំនូកកណ្តៀរ ហើយប្រើដៃរបស់វាដើម្បីកៀរកណ្តៀរ។ ការប្រើឧបករណ៍ខុសគ្នានេះអាចមកពីលក្ខណៈបរិស្ថាន ដោយអាហ្វ្រិកខាងលិចមានភ្លៀងធ្លាក់ច្រើន ធ្វើឱ្យដីពំនូកកណ្តៀរទន់ ងាយស្រួលក្នុងការបំបែកជាងនៅអាហ្វ្រិកខាងកើត។

*ប៊ែកណារដ៍ ស្តែន* (Bernhard Stern) លើកឡើងថា សត្វមានតែឥរិយបថសង្គមប៉ុណ្ណោះ មិនមានឥរិយាបថវប្បធម៌ទេ។ ឥរិយាបថរបស់សត្វទាំងនោះមានលក្ខណៈជាតំណពូជបែបសភាវគតិ មិនមែនកើតឡើងតាមរយៈការរៀនសូត្រនោះទេ។ ជាងនេះទៀត ភាពខុសគ្នារវាង *ជីវិតវប្បធម៌* និង *ជីវិតសង្គម* គឺភាសា។ យោងតាមភស្តុតាងនរវិទ្យា ភាពខុសគ្នាជាមូលដ្ឋានរវាងជីវិតវប្បធម៌របស់មនុស្សនិងជីវិតសង្គមរបស់សត្វ គឺមនុស្សអាចបង្កើតភាសានិងការអាន ឯសត្វគឺមិនអាចទេ។

## សេចក្តីសន្និដ្ឋាន

ជារួម ការពិចារណាអំពីថាតើចំពូកសត្វមានវប្បធម៌ឬអត់ ជាពិសេសគឺការពិចារណាលើបុព្វថនិកសត្វ ដែលគេយល់ថាជាបុព្វមនុស្ស គឺពុំមានការឯកភាពគ្នាទេ ដោយសារការផ្តល់និយមន័យដល់បញ្ញត្តិ *វប្បធម៌* ពុំមានការឯកភាព។ ទោះជាយ៉ាងណា អ្នកប្រាជ្ញភាគច្រើនយល់ថា វប្បធម៌មានតែនៅក្នុងចំពូកមនុស្សប៉ុណ្ណោះ ឯចំពូកសត្វមានត្រឹមជីវិតសង្គម។

ក្នុងន័យទស្សនវិជ្ជា មនុស្សខុសពីសត្វនិងខ្ពង់ខ្ពស់ប្រសើរជាងសត្វ ដោយមនុស្សមានវិចារណញ្ញាណប្រកបដោយសីលធម៌ ឯសត្វមានត្រឹមសភាវគតិប៉ុណ្ណោះ។